

# ទទួលពររួមជាមួយលោកអប្រាហាំ

## 7. BLESSED ALONG WITH ABRAHAM

Copyright © 2005, 2018 Barnabas Mam



វត្ថុបំណង

រៀនឲ្យដឹងថា

តើអ្នកបានរួចពីបណ្តាសាដែលមកពីក្រឹត្យវិន័យដោយរបៀបណា

តើអ្នកបានទទួលពររួមជាមួយលោកអប្រាហាំដោយរបៀបណា

ដើម្បីឲ្យអ្នកអាចរស់នៅជាមនុស្សប្រកបដោយពររបស់លោកអប្រាហាំ

និងចេះចែករំលែកពរនេះដល់អ្នកដទៃដោយសេចក្តីស្រឡាញ់។

១.លោកអប្រាហាំបានសុចរិតដោយសារជំនឿ
1. ABRAHAM WAS COUNTED AS RIGHTEOUSNESS BY FAITH
កាឡាទី ៣:៦-៧
៦ លោកអប្រាហាំជឿលើព្រះជាម្ចាស់
ហើយព្រះអង្គប្រោសលោកឲ្យ បានសុចរិត ដោយយល់ដល់ជំនឿនេះ។
៧ ដូច្នេះសូមបងប្អូនយល់ថា
អ្នកណាមានជំនឿអ្នកនោះហើយជាកូនចៅរបស់លោកអប្រាហាំ។

ព្រះជាម្ចាស់ប្រោសលោកអប្រាហាំឲ្យបានសុចរិត
( Abraham was counted as righteousness )
ដោយយល់ដល់ជំនឿរបស់លោកសុទ្ធសាធ( only by faith )
មិនមែនដោយយល់ដល់ការប្រព្រឹត្តល្អរបស់លោកនោះឡើយ( not by work ) ។

លោកុប្បត្តិ ១៥:៥-៦
៥ ព្រះអង្គនាំលោកចេញទៅក្រៅហើយមានព្រះបន្ទូលថា៖
«ចូរងើយមើលទៅលើមេឃហើយរាប់ចំនួនផ្កាយមើល៍ តើអ្នកអាចរាប់អស់ទេ ?»។
ព្រះអង្គមានព្រះបន្ទូលថែមទៀតថា៖
«ពូជពង្សរបស់អ្នកក៏នឹងមានចំនួនច្រើនដូចផ្កាយទាំងនោះដែរ»។
៦ លោកអាប់រ៉ាមជឿលើព្រះអម្ចាស់
ហើយដោយយល់ដល់ជំនឿនេះ ព្រះអង្គប្រោសលោកឲ្យ បានសុចរិត។

ដោយសារលោកអប្រាហាំជឿថាព្រះជាម្ចាស់នឹងធ្វើឲ្យលោកមានពូជពង្សជាច្រើន
គឺពូជពង្សខាងវិញ្ញាណដែលមានចំនួនច្រើនដូចផ្កាយលើមេឃ
( ពូជពង្សខាងវិញ្ញាណ spiritual offspring កូនខាងវិញ្ញាណ spiritual children )
ព្រះអម្ចាស់បានរាប់លោកជាសុចរិតដោយយល់ដល់ជំនឿនេះ។
តារាមួយដួងៗរបស់លោកអប្រាហាំតំណាងឲ្យបុគ្គលម្នាក់ៗដែលមានជំនឿលើព្រះគ្រិស្ត។



ដោយសារលោកអប្រាហាំជឿលើព្រះអម្ចាស់ដែលធ្វើឲ្យលោកមានពូជពង្សជាច្រើន
ដូចផ្កាយលើមេឃ ព្រះអង្គប្រោសលោកឲ្យបានសុចរិតដោយយល់ដល់ជំនឿនេះ។

២.អ្នកមានជំនឿលើព្រះគ្រិស្តជាកូនរបស់លោកអប្រាហាំ
2. THE BELIEVERS OF CHRIST ARE SONS OF ABRAHAM
កាឡាទី ៣:៦-៧
៦ លោកអប្រាហាំជឿលើព្រះជាម្ចាស់
ហើយព្រះអង្គប្រោសលោកឲ្យបានសុចរិតដោយយល់ដល់ជំនឿនេះ។
៧ ដូច្នេះសូមបងប្អូនយល់ថា
អ្នកណាមានជំនឿអ្នកនោះហើយជា កូនចៅ របស់លោកអប្រាហាំ។

យើងម្នាក់ៗក្លាយជាតារាមួយដួងរបស់លោកអប្រាហាំ
( តារា star កូន son ពូជ seed ពូជពង្ស offspring, descendant )
ដោយសារជំនឿរបស់យើងសុទ្ធសាធ( only by faith )
មិនមែនដោយសារការប្រព្រឹត្តល្អរបស់យើងនោះឡើយ( not by work ) ។

៣.អ្នកមានជំនឿលើព្រះគ្រិស្តបានសុចរិតដោយសារជំនឿ
3. THE BELIEVERS OF CHRIST ARE JUSTIFIED BY FAITH
កាឡាទី ៣:៨-៩
៨ ក្នុងគម្ពីរមានគ្រោងទុកជាមុនថា
ព្រះជាម្ចាស់នឹងប្រោសសាសន៍ដទៃឲ្យបានសុចរិតដោយសារ ជំនឿ
ហើយលោកអប្រាហាំបានទទួលដំណឹងល្អនេះជាមុនថា
«ជាតិសាសន៍ទាំងអស់នឹងទទួលពរដោយសារអ្នក»។
៩ ហេតុនេះអស់អ្នកដែលមានជំនឿ
ក៏បានទទួលព្រះពររួមជាមួយលោកអប្រាហាំដែលជាអ្នកមានជំនឿនោះដែរ។

ព្រះជាម្ចាស់ប្រោសយើងដែលជាសាសន៍ដទៃឲ្យបានសុចរិត
ដោយសារជំនឿរបស់យើងសុទ្ធសាធ
មិនមែនដោយសារការប្រព្រឹត្តល្អរបស់យើងនោះឡើយ។

៤.អ្នកមានជំនឿលើព្រះគ្រិស្តបានទទួលពររួមជាមួយលោកអប្រាហាំ
4. THE BELIEVERS OF CHRIST ARE BLESSED ALONG WITH ABRAHAM
កាឡាទី ៣:៨-៩
៨ ក្នុងគម្ពីរមានគ្រោងទុកជាមុនថា
ព្រះជាម្ចាស់នឹងប្រោសសាសន៍ដទៃឲ្យបានសុចរិតដោយសារជំនឿ
ហើយលោកអប្រាហាំបានទទួលដំណឹងល្អនេះជាមុនថា
«ជាតិសាសន៍ទាំងអស់នឹងទទួលពរដោយសារអ្នក»។
៩ ហេតុនេះអស់អ្នកដែលមានជំនឿ
ក៏ បានទទួលព្រះពរ រួមជាមួយលោកអប្រាហាំដែលជាអ្នកមានជំនឿនោះដែរ។

ដោយសារយើងមានជំនឿលើព្រះគ្រិស្ត យើងដែលជាសាសន៍ដទៃសោះ
ក៏បានទទួលការប្រោសឲ្យសុចរិត បានក្លាយជាបុត្ររបស់លោកអប្រាហាំ
និងបានទទួលពររួមជាមួយលោកអប្រាហាំដូចលោកអ៊ីសាកដែរ។

ក.ក្រុមគ្រួសារទាំងអស់នៅលើផែនដីនឹងបានទទួលពរដោយសារលោកអប្រាហាំ
A. ALL THE FAMILIES OF THE EARTH SHALL BE BLESSED IN ABRAHAM
លោកុប្បត្តិ ១២:២-៣
២ យើងនឹងឲ្យប្រជាជាតិមួយដ៏ធំកើតចេញពីអ្នក
ហើយយើងនឹងឲ្យពរអ្នក។ យើងនឹងធ្វើឲ្យអ្នកមានឈ្មោះល្បី។
ដូច្នេះចូរធ្វើជាអ្នកផ្ដល់ពរដល់អ្នកដទៃចុះ!។
៣ យើងនឹងឲ្យពរដល់ជនទាំងឡាយណាដែលឲ្យពរអ្នក
យើងក៏នឹងដាក់បណ្ដាសាដល់ជនទាំងឡាយណាដែលដាក់បណ្ដាសាអ្នកដែរ
ក្រុមគ្រួសារទាំងអស់ នៅលើផែនដីនឹងបានទទួលពរដោយសារអ្នក»។

កាលពីអំឡុង ២០០០ឆ្នាំ មុនគ្រិស្តសករាជ ព្រះជាម្ចាស់ត្រាស់ហៅលោកអាប៉្រាម
ឲ្យចាកចេញពីក្រុងអ៊ើរនៃស្រុកខាល់ដេគឺមេសូប៉ូតាមាភាគខាងត្បូង(អ៊ីរ៉ាក់បច្ចុប្បន្ន)។
ពេលនោះព្រះជាម្ចាស់បានប្រទានសម្បថ(ព្រះបន្ទូលសន្យា)ប្រាប់ប្រការដល់លោក។
ព្រះអង្គថែមទាំងសន្យាថាក្រុមគ្រួសារទាំងអស់នៅលើផែនដីនឹងបានទទួលពរដោយសារលោក។

សម្បថនៃសម្ពន្ធមេត្រីលោកអប្រាហាំ (THE VOW OF ABRAHAMIC COVENANT)
សម្ពន្ធមេត្រីរបស់លោកអាប៉្រាមជាសម្ពន្ធមេត្រីឥតលក្ខខណ្ឌ(unconditional covenant)។
ជាបឋមព្រះជាម្ចាស់បានប្រទានសម្បថនៃសម្ពន្ធមេត្រីប្រាំប្រការដល់លោកអាប៉្រាម
ដូចមានចែងទុកក្នុង លោកុប្បត្តិ ១២:២-៣ ដែលមានខ្លឹមសារដូចតទៅ៖
១.ព្រះអម្ចាស់នឹងធ្វើឲ្យប្រជាជាតិហេប្រើ(អ៊ីប្រ៊ី עִבְרִי)កើតចេញពីលោកអាប៉្រាម(ខ២)
២.ព្រះអម្ចាស់នឹងប្រទានពរដល់លោកអាប៉្រាម(ខ២)
៣.ព្រះអម្ចាស់នឹងធ្វើឲ្យលោកអាប៉្រាមមានកេរ្តិ៍ឈ្មោះល្បីល្បាញ(ខ២)
ឈ្មោះរបស់លោកអាប៉្រាមក្នុងភាសាហេប្រើមានន័យថា«បិតាដែលគេលើកតម្កើង»
៤.ព្រះអម្ចាស់នឹងការពារលោកអាប៉្រាមពីពួកសត្រូវ(ខ៣)
៥.ព្រះអម្ចាស់នឹងធ្វើឲ្យគ្រួសារទាំងអស់បានព្រះពរតាមរយៈលោកអាប៉្រាម(ខ៣)

សម្បថទីប្រាំនៃសម្ពន្ធមេត្រីនេះបានសម្រេចតាមរយៈព្រះគ្រិស្តដែលជាពូជរបស់លោកអាប៉្រាម។
(សម្ពន្ធមេត្រី covenant សន្ធិសញ្ញា treaty កិច្ចសន្យា contract កិច្ចព្រមព្រៀង agreement)។

ខ.ក្រុមគ្រួសារទាំងអស់នៅលើផែនដីនឹងបានទទួលពរតាមរយៈព្រះគ្រិស្ត
B. ALL THE FAMILIES OF THE EARTH SHALL BE BLESSED IN CHRIST
លោកុប្បត្តិ ២៨:១៤
១៤ ពូជពង្សរបស់អ្នកនឹងមានចំនួនច្រើនដូចធូលីដី។
ទឹកដីរបស់អ្នកនឹងលាតសន្ធឹងទៅទិសខាងលិច
ទិសខាងកើត ទិសខាងជើង និងទិសខាងត្បូង។
ក្រុមគ្រួសារទាំងអស់នៅលើផែនដីនឹងបានទទួលពរដោយសារអ្នកនិង ពូជពង្សរបស់អ្នក។

កិច្ចការ ៣:២៥
២៥ បងប្អូនហ្នឹងហើយជាកូនចៅរបស់ព្យាការីហើយបងប្អូនក៏ចូលរួម
ក្នុងសម្ពន្ធមេត្រីដែលព្រះជាម្ចាស់បានចងជាមួយបុព្វបុរសដែរ
ដូចព្រះអង្គមានព្រះបន្ទូលទៅកាន់លោកអប្រាហាំថា
"ក្រុមគ្រួសារទាំងអស់នៅផែនដីនឹងទទួលពរតាមរយៈ ពូជពង្សរបស់អ្នក"។



ព្រះជាម្ចាស់មានព្រះបន្ទូលសន្យាដល់លោកអប្រាហាំនិងដល់ពូជពង្សរបស់លោក។
ក្នុងគម្ពីរពុំមានចែងថា«ដល់ពូជពង្សទាំងឡាយ»ដូចជាចង់សំដៅទៅលើពូជពង្សដ៏ច្រើនឡើយគឺ
សំដៅទៅលើពូជពង្សតែម្នាក់ប៉ុណ្ណោះ:«ដល់ពូជពង្សរបស់អ្នក»ពោលគឺព្រះគ្រិស្ត។



អ្នកមានជំនឿលើព្រះគ្រិស្តសុទ្ធតែជាបុត្ររបស់ព្រះជាម្ចាស់(កាឡាទី ៣:២៦)
និងជាបុត្ររបស់លោកអប្រាហាំ(កាឡាទី ៣:៧)
ដែលត្រូវទទួលពររួមជាមួយលោកអប្រាហាំដែរ(កាឡាទី ៣:៩)។

គ.ចំណុចពិសេសប្រាំពីរយ៉ាងនៃសម្ពន្ធមេត្រីលោកអប្រាហាំ(លោកុប្បត្តិ ១៧)

C. 7 IMPORTANT POINTS OF ABRAHAMIC COVENANT(GENESIS 17)

១.ភាគីនៃសម្ពន្ធមេត្រី Parties : ព្រះអម្ចាស់និងលោកអប្រាហាំ(១២)

២.សម្បថនៃសម្ពន្ធមេត្រី Vow : ព្រះអម្ចាស់នឹងធ្វើឲ្យពូជពង្សរបស់លោកកើនចំនួនច្រើនជាអនេក(១២) ព្រះអង្គនឹងធ្វើឲ្យលោកក្លាយជាឪពុកនៃប្រជាជាតិដ៏ច្រើន(១៤-១៥)

៣.ការកាត់ឈ្មោះនៃសម្ពន្ធមេត្រី Cut of Name : គេលែងហៅអ្នកថា“អាប៊ីរ៉ាម”ទៀតហើយ តែអ្នកនឹងមានឈ្មោះថា“អប្រាហាំ”វិញ(១៥)

៤.អ្នកទទួលផលនៃសម្ពន្ធមេត្រី Beneficiaries : ពូជពង្សអប្រាហាំគ្រប់ប្រជាជាតិ(១៦-១៧)

៥.សុពលភាពនៃសម្ពន្ធមេត្រី Validity : សម្ពន្ធមេត្រីនេះនឹងនៅស្ថិតស្ថេរជាដរាប(១៧)

៦.សញ្ញាសម្គាល់នៃសម្ពន្ធមេត្រី Sign : ពិធីកាត់ស្បែកសម្រាប់បុរសទាំងអស់ដែលជាពូជពង្សរបស់លោកអប្រាហាំនិងជាអ្នកបម្រើរបស់លោកអប្រាហាំ(១១០-១១៣)

៧.ថ្ងៃឆ្លងសម្ពន្ធមេត្រី Dedication : ពេលលោកអប្រាហាំអាយុ៩៩ឆ្នាំ អ៊ីស្មាអែលអាយុ១៣ឆ្នាំ (១២៤-១២៦) បំណោរតមកគេធ្វើពិធីកាត់ស្បែកនេះពេលទារកប្រុសមានអាយុ៨ថ្ងៃ(១១២)

## ឃ.យើងមានចំណែកនៅក្នុងសម្ពន្ធមេត្រីលោកអប្រាហាំដោយសារព្រះគ្រិស្ដ

D. WE TAKE PARTS IN ABRAHAMIC COVENANT THROUGH CHRIST

អេភេសូ ២:១១-១៤

១១ ដូច្នេះ សូមបងប្អូនចងចាំថាៈពីដើមបងប្អូនកើតមកជាសាសន៍ដទៃ
ហើយសាសន៍យូដាដែលចាត់ទុកថាខ្លួនជា«ពួកកាត់ស្បែក»
ហៅបងប្អូនថា«ពួកមិនកាត់ស្បែក»ព្រោះគេសំគាល់ទៅលើសញ្ញាមួយដែលគេធ្វើលើរូបកាយ។
១២ កាលណោះ បងប្អូននៅឆ្ងាយពីព្រះគ្រិស្ដ គ្មានសិទ្ធិចូលជាតិអ៊ីស្រាអែល
គ្មានទំនាក់ទំនងអ្វីនឹង សម្ពន្ធមេត្រី ដែលចងឡើងដោយព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ទេ
បងប្អូនរស់នៅក្នុងលោកនេះដោយ គ្មានទីសង្ឃឹម ហើយក៏គ្មានព្រះជាម្ចាស់ដែរ។
១៣ កាលពីដើមបងប្អូននៅឆ្ងាយមែន ក៏ប៉ុន្តែឥឡូវនេះដោយបងប្អូនរួមក្នុងអង្គព្រះយេស៊ូគ្រិស្ដ
បងប្អូនបានមកនៅជិតដោយសារព្រះលោហិតរបស់ព្រះគ្រិស្ដ។
១៤ គឺព្រះគ្រិស្ដហើយដែលជាសន្តិភាពរបស់យើង
ព្រះអង្គ បានប្រមូលសាសន៍ទាំងពីរឲ្យរួមគ្នាមកជាប្រជារាស្ត្រតែមួយ។

## ង.យើងបានទទួលពិធីកាត់ស្បែកតាមរបៀបព្រះគ្រិស្ដ

E. WE WERE CIRCUMCISED WITH THE CIRCUMCISION OF CHRIST

កូឡុស ២:១១-១២

១១ ក្នុងអង្គព្រះគ្រិស្ដ បងប្អូនក៏បានទទួលពិធីកាត់ស្បែកដែរ
តែមិនមែនដោយដៃមនុស្សទេ។ គឺបងប្អូនបានទទួល ពិធីកាត់ស្បែកតាមរបៀបព្រះគ្រិស្ដ
ដោយដោះរូបកាយដែលជាប់និស្ស័យលោកីយ៍នេះចេញ។
១២ ពេលបងប្អូនទទួលពិធីជ្រមុជទឹកបងប្អូនត្រូវកប់ក្នុងផ្នូររួមជាមួយព្រះគ្រិស្ដហើយ
ដោយបងប្អូនរួមក្នុងអង្គព្រះគ្រិស្ដ បងប្អូនក៏មានជីវិតរស់ឡើងវិញរួមជាមួយព្រះអង្គដែរ
ព្រោះបងប្អូនមានជំនឿលើឫទ្ធានុភាពរបស់ព្រះជាម្ចាស់
ដែលបានប្រោសព្រះគ្រិស្ដឲ្យមានព្រះជន្មរស់ឡើងវិញ។

សាសន៍អ៊ីស្រាអែលយកពិធីកាត់ស្បែកមកធ្វើជាសញ្ញាសម្គាល់នៃសម្ពន្ធមេត្រីលោកអប្រាហាំ។
អ្នកជឿយកពិធីជ្រមុជទឹកក្នុងនាមព្រះយេស៊ូធ្វើជាសញ្ញាសម្គាល់នៃសម្ពន្ធមេត្រីលោកអប្រាហាំ។

ច.យើងបានទទួលពិធីកាត់ស្បែកស្របតាមព្រះវិញ្ញាណ

E. WE WERE CIRCUMCISED BY THE SPIRIT

រ៉ូម ២:២៨-២៩

២៨ សាសន៍យូដាដ៏ពិតប្រាកដមិនស្ថិតនៅត្រង់សំបកក្រៅទេ
រីឯការកាត់ស្បែកដ៏ពិតប្រាកដក៏មិនស្ថិតនៅត្រង់សញ្ញាលើរូបកាយនោះដែរ
២៩ សាសន៍យូដាដ៏ពិតប្រាកដសំដៅទៅផ្នែកខាងក្នុងចិត្តឯណោះវិញ
រីឯការកាត់ស្បែកដ៏ពិតប្រាកដក៏ស្ថិតនៅលើចិត្តដែរគឺជា ការកាត់ស្បែកស្របតាមព្រះវិញ្ញាណ
មិនមែនតាមគម្ពីរវិន័យជាលាយលក្ខណ៍អក្សរនោះឡើយ។
សាសន៍យូដាប្រភេទនេះទទួលការកោតសរសើរពីព្រះជាម្ចាស់មិនមែនពីសំណាក់មនុស្សទេ។

អ្នកជឿព្រះគ្រិស្តជាបុត្ររបស់លោកអប្រាហាំខ្សែខាងលោកស្រីសារ៉ា
ស្របតាមសម្ពន្ធមេត្រីអប្រាហាំ ( Abrahamic Covenant ) ឬសម្ពន្ធមេត្រីថ្មី ( New Covenant )
ដូចអ៊ីសាកជាបុត្រដែលព្រះអម្ចាស់សន្យាបំពោះលោកអប្រាហាំដែរ ( កាឡាទី ៤:២៧-២៨ ) ។

៥.ព្រះគ្រិស្តបានទទួលបណ្តាសាជំនួសយើងដើម្បីឲ្យយើងបានទទួលពរ

5. CHRIST BECAME A CURSE FOR US SO WE ARE BLESSED

កាឡាទី ៣:១៣-១៤

១៣ ដោយព្រះគ្រិស្ត បានទទួលបណ្តាសាសំរាប់យើង
ទ្រង់លោះយើងឲ្យរួចផុតពីបណ្តាសាដែលមកពីក្រឹត្យវិន័យ ដ្បិតមានចែងទុកមកថា
«អ្នកណាដែលត្រូវគេព្យួរជាប់នឹងឈើអ្នកនោះត្រូវបណ្តាសាហើយ!»។
១៤ ហេតុការណ៍នេះកើតមានដូច្នេះដើម្បីឲ្យព្រះពរដែលលោកអប្រាហាំទទួល
បានហូរទៅដល់ សាសន៍ដទៃតាមរយៈព្រះគ្រិស្តយេស៊ូ ដែរ
ហើយឲ្យយើងទទួលព្រះវិញ្ញាណ
ដែលព្រះជាម្ចាស់បានសន្យាប្រទានមកដោយយើងមានជំនឿ។

ដោយក្តីមេត្តាព្រះគ្រិស្តបានយកបណ្តាសារបស់យើងទៅផ្ទុកលើអង្គទ្រង់នៅលើឈើឆ្កាង ។
ដោយសារព្រះគុណព្រះអង្គបានប្រទានពររបស់លោកអប្រាហាំនិងព្រះវិញ្ញាណដល់យើង ។

## ក.រឿងអាក្រក់ទាំងប៉ុន្មានដែលព្រះគ្រិស្តបានទទួលជំនួសយើងនៅលើឈើឆ្កាង
## A. ALL THE BAD THINGS IMPUTED TO CHRIST ON THE CROSS



| | |
|---|---|
| អំពើបាប | sin |
| ពិរុទ្ធភាព | guilt |
| ព្រះពិរោធរបស់ព្រះជាម្ចាស់ | the wrath of God |
| ការបោះបង់ចោល | rejection |
| ការបែកចេញពីព្រះជាម្ចាស់ | separation from God |
| អសមត្ថភាព | incompetence |
| ការដាក់ទោស | condemnation |
| ទារុណកម្ម | chastisement |
| ការសោកសៅ | sorrow |
| ស្នាមរបួស | wounds |
| សេចក្ដីស្លាប់ | death |
| បណ្ដាសានៃក្រឹត្យវិន័យ | the curse of the law |

## ខ.រឿងល្អទាំងប៉ុន្មានដែលព្រះគ្រិស្តបានប្រទានមកយើងនៅលើឈើឆ្កាង
## B. ALL THE GOOD THINGS IMPUTED TO US ON THE CROSS



| | |
|---|---|
| សេចក្ដីសុចរិត | righteousness |
| ភាពគ្មានទោស | innocence |
| ការគាប់ព្រះហឫទ័យរបស់ព្រះ | the favor of God |
| ការទទួលស្គាល់ | acceptance |
| ការនៅរួមជាមួយព្រះជាម្ចាស់ | union with God |
| សមត្ថភាព | competence |
| ការលើកលែងទោស | forgiveness |
| សេចក្ដីសុខសាន្ត | peace |
| អំណរ | joy |
| ការប្រោសឲ្យជា | healings |
| ជីវិតអស់កល្បជានិច្ច | eternal life |
| ពររួមជាមួយលោកអប្រាហាំ | blessing of Abraham |

## គ.ពរដែលអ្នកជឿត្រូវទទួលរួមជាមួយលោកអប្រាហាំ
## C. THE BLESSING THE BELIVERS ARE TO RECEIVE WITH ABRAHAM

- ពរខាងសង្គម – មានគេស្រឡាញ់រាប់អាន(finding favor with men)
- ពរខាងសម្ភារៈ – មានជីវភាពសំបូណ៌សប្បាយ(wealth and prosperity)
- ពរខាងសតិបញ្ញា – មានប្រាជ្ញានិងសុភនិច្ឆ័យ(wisdom and sound judgement)
- ពរខាងរូបកាយ – មានសុខភាពល្អនិងអាយុយឺនយូរ(long and healthy life)
- ពរខាងប្រជាជន – ជាឪពុករបស់ប្រជាជាតិដ៏ច្រើន គឺឪពុករបស់កូនធម្មតានិងឪពុករបស់កូនខាងវិញ្ញាណ(father of many children )
- ពរខាងអាជ្ញាសិទ្ធិ – មានអំណាចលើពួកខ្មាំងសត្រូវទាំងអស់(dominion over enemies)
- ពរខាងវិញ្ញាណ – ចូលក្នុងព្រះរាជ្យនៃស្ថានបរមសុខ(entering the kingdom of heaven)

ទី១.ពរខាងសង្គម SOCIAL BLESSING – មានគេស្រឡាញ់រាប់អាន

លោកុប្បត្តិ ១២:២

២ យើងនឹងឲ្យប្រជាជាតិមួយដ៏ធំកើតចេញពីអ្នក
ហើយយើងនឹងឲ្យពរអ្នក។ យើងនឹងធ្វើឲ្យអ្នកមាន ឈ្មោះល្បី។
ដូច្នេះ ចូរធ្វើជាអ្នកផ្តល់ពរដល់អ្នកដទៃចុះ!។

លោកុប្បត្តិ ១២:១៦

១៦ រីឯលោកអាប់រ៉ាមវិញ គេ រាប់រកលោក ដោយមេត្រីព្រោះតែភរិយារបស់លោក។
គេបានយកចៀម គោ លា អ្នកបំរើប្រុសស្រី លាញី និងអូដ្ឋមកជូនលោកអាប់រ៉ាម។

ទី២.ពរខាងសម្ភារៈ MATERIAL BLESSING – មានជីវភាពសំបូណ៌សប្បាយ
លោកុប្បត្តិ ១៣:១-២,១៤-១៥
១ លោកអាប់រ៉ាមបានវិលត្រឡប់មកពីស្រុកអេស៊ីបវិញឆ្ពោះទៅកាន់តំបន់ណេកិប
ជាមួយភរិយានិងអ្វីៗដែលជាកម្មសិទ្ធិរបស់លោក។ លោកឡុតក៏មកជាមួយដែរ។
២ លោកអាប់រ៉ាមមាន ហ្វូងសត្វ និងមាន មាសប្រាក់ ជាច្រើន។
១៤ ក្រោយពេលលោកឡុតបែកចេញពីលោកអាប់រ៉ាមទៅ
ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកអាប់រ៉ាមថា៖
«ចូរងើបមុខមើលពីកន្លែងដែលអ្នកនៅនោះហើយសម្លឹងឆ្ពោះទៅ
ទិសខាងជើង និងទិសខាងត្បូង ទិសខាងកើត និងទិសខាងលិចទៅ!
១៥ ដ្បិតយើងនឹងប្រគល់ ស្រុកទាំងមូល ដែលអ្នកមើលឃើញនេះ
ឲ្យអ្នកនិងឲ្យពូជពង្សរបស់អ្នករហូតតទៅ។



លោកអាប់រ៉ាមបានវិលត្រឡប់មកពីស្រុកអេស៊ីបវិញឆ្ពោះទៅកាន់តំបន់ណេកិបជាមួយភរិយា
និងអ្វីៗដែលជាកម្មសិទ្ធិរបស់លោក។ លោកអាប់រ៉ាមមានហ្វូងសត្វនិងមានមាសប្រាក់ជាច្រើន។

ទី៣.ពរខាងសតិបញ្ញា INTELLECTUAL BLESSING – មានប្រាជ្ញានិងសុភនិច្ឆ័យ
លោកុប្បត្តិ ១៥:២-៤
២ លោកអាប់រ៉ាមទូលតបវិញថា៖
«បពិត្រព្រះជាអម្ចាស់ ព្រះអង្គប្រទានអ្វីមកទូលបង្គំក៏ឥតប្រយោជន៍ដែរ
ព្រោះទូលបង្គំនឹងលាចាកលោកនេះទៅទាំង គ្មានកូន។
រីឯអ្នកដែលនឹងទទួលកេរមត៌ករបស់ទូលបង្គំ
គឺអេលាស៊ើរជាអ្នកក្រុងដាម៉ាស់ឯណោះវិញ»។
៣ លោកមានប្រសាសន៍ទៀតថា៖
«ព្រះអង្គពុំបានប្រទានឲ្យទូលបង្គំមានកូនបន្តពូជសោះ
គឺមានតែអ្នកបំរើក្នុងក្រុមគ្រួសាររបស់ទូលបង្គំប៉ុណ្ណោះ
ដែលនឹងទទួលកេរមត៌កតពីទូលបង្គំ»។
៤ ប៉ុន្តែ ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកថា៖
«មិនមែនអ្នកបំរើទេគឺកូនដែលនឹងកើតចេញពីអ្នកវិញឯណោះជាអ្នកទទួលមត៌ក»។

ទី៤.ពរខាងរូបកាយ PHYSICAL BLESSING – មានសុខភាពល្អនិងអាយុយឺនយូរ
លោកុប្បត្តិ ១៥:១៥
១៥ រីឯអ្នកវិញអ្នកនឹងទៅជួបជុំជាមួយបុព្វបុរសរបស់អ្នកដោយសុខសាន្ត
ហើយគេនឹងបញ្ចុះសពអ្នកក្រោយពីអ្នកបានរស់យ៉ាងសុខក្សេមក្សាន្ត អាយុយឺនយូរ។

លោកុប្បត្តិ ២៥:៧-៨
៧ លោកអប្រាហាំរស់បានទាំងអស់មួយរយចិតសិបប្រាំឆ្នាំ។
៨ បន្ទាប់មកលោកអប្រាហាំទទួលមរណភាពទៅ
គឺក្រោយពីលោករស់យ៉ាងយូរប្រកបដោយសុភមង្គល
មាន អាយុយឺនយូរ សម្បូណ៌សប្បាយមក
លោកក៏បានទៅជួបជុំនឹងបុព្វបុរសរបស់លោកដែលចែកស្ថានទៅហើយ។

ទី៥.ពរខាងប្រជាជន DEMOGRAPHIC BLESSING – ជាឪពុករបស់ប្រជាជាតិដ៏ច្រើន
លោកុប្បត្តិ ១៧:២-៦
២ យើងនឹងចងសម្ពន្ធមេត្រីជាមួយអ្នក
យើងនឹងធ្វើឲ្យពូជពង្សរបស់អ្នកកើនចំនួនច្រើនជាអនេក»។
៣ លោកអាប់រ៉ាមក្រាបចុះអោនមុខដល់ដី ហើយព្រះជាម្ចាស់មានព្រះបន្ទូល
មកលោកថា៖ ៤ «ចំណែកយើង យើងចងសម្ពន្ធមេត្រីជាមួយអ្នកដូចតទៅ:
អ្នកនឹងបានទៅជាឪពុករបស់ប្រជាជាតិដ៏ច្រើន
៥ គេលែងហៅអ្នកថា"អាប់រ៉ាម"ទៀតហើយ តែអ្នកនឹងមានឈ្មោះថា"អប្រាហាំ"វិញ
ដ្បិតយើងនឹងធ្វើឲ្យអ្នកបានទៅជាឪពុករបស់ប្រជាជាតិដ៏ច្រើន។
៦ យើងនឹងធ្វើឲ្យអ្នកមាន កូនចៅច្រើនជាអនេក
យើងនឹងធ្វើឲ្យអ្នកបង្កើតប្រជាជាតិជាច្រើន
ហើយនឹងមាន ស្ដេចជាច្រើន កើតចេញពីអ្នកដែរ។



គេលែងហៅអ្នកថា"អាប់រ៉ាម"ទៀតហើយ តែអ្នកនឹងមានឈ្មោះថា"អប្រាហាំ"វិញ
ដ្បិតយើងនឹងធ្វើឲ្យអ្នកបានទៅជាឪពុករបស់ប្រជាជាតិដ៏ច្រើន។(លោកុប្បត្តិ ១៧:៥)

ទី៦.ពរខាងអាជ្ញាសិទ្ធិ AUTHORITATIVE BLESSING – មានអំណាចលើពួកខ្មាំងសត្រូវ
លោកុប្បត្តិ ២២:១៧
១៧ យើងនឹងប្រទានពរដល់អ្នកដ៏ច្រើនបរិបូណ៌យ៉ាងនោះដែរ
យើងនឹងធ្វើឲ្យពូជពង្សរបស់អ្នកកើនចំនួនច្រើនឡើង
ដូចផ្កាយនៅលើមេឃ និងដូចគ្រាប់ខ្សាច់នៅឆ្នេរសមុទ្រ។
ពូជពង្សអ្នក នឹងគ្រប់គ្រង លើនគររបស់ពួកខ្មាំងសត្រូវ។

ពូជពង្សរបស់អប្រាហាំដែលមានទាំងពូជធម្មតា(ជនជាតិអ៊ីស្រាអែល)
និងពូជខាងវិញ្ញាណ(ជាតិសាសន៍ដទៃដែលជឿលើព្រះគ្រិស្ត)
មានអាជ្ញាសិទ្ធិឡើងធ្វើជាមេគ្រប់គ្រងរបស់គេមិនមែនធ្វើជាខ្ញុំកញ្ជះរបស់គេនោះឡើយ។

ទី៧.ពរខាងវិញ្ញាណ SPIRITUAL BLESSING – ចូលក្នុងព្រះរាជ្យនៃស្ថានបរមសុខ
ម៉ាថាយ ៨:១០-១១
១០ ...ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា
ខ្ញុំមិនដែលឃើញនរណាមានជំនឿបែបនេះនៅស្រុកអ៊ីស្រាអែលឡើយ។
១១ ខ្ញុំសុំប្រាប់អ្នករាល់គ្នាថានឹងមានមនុស្សជាច្រើនពីទិសខាងកើតនិងទិសខាងលិច
មកចូលរួមពិធីជប់លៀងក្នុងព្រះរាជ្យនៃ ស្ថានបរមសុខ
ជាមួយលោកអប្រាហាំ លោកអ៊ីសាក និងលោកយ៉ាកុប។

លូកា ១៦:២២
២២ ថ្ងៃមួយ អ្នកក្រនោះស្លាប់ទៅ
ពួកទេវតានាំគាត់យកទៅដាក់ក្បែរលោកអប្រាហាំនៅ ស្ថានបរមសុខ។

ពេលស្លាប់ភ្លាម ពួកទេវតាមកនាំវិញ្ញាណក្ខន្ធរបស់អ្នកស្លាប់ក្នុងព្រះគ្រិស្តទៅស្ថានបរមសុខភ្លាម។

## ទទួលពររួមជាមួយលោកអប្រាហាំ

អ្នកមានជំនឿលើព្រះគ្រិស្តបានទទួលពររួមជាមួយលោកអប្រាហាំដូចតទៅ៖

- ពរខាងសង្គម(Social Blessing) – មានគេស្រឡាញ់រាប់អាន
- ពរខាងសម្ភារៈ(Material Blessing) – មានជីវភាពសំបូណ៌សប្បាយ
- ពរខាងសតិបញ្ញា(Intellectual Blessing) – មានប្រាជ្ញានិងសុភនិច្ឆ័យ
- ពរខាងរូបកាយ(Physical Blessing) – មានសុខភាពល្អនិងអាយុយឺនយូរ
- ពរខាងប្រជាជន(Demographic Blessing)– ជាឪពុករបស់ប្រជាជាតិដ៏ច្រើន គឺឪពុករបស់កូនធម្មតានិងឪពុករបស់កូនខាងវិញ្ញាណ
- ពរខាងអាជ្ញាសិទ្ធិ(Authoritative Blessing) – មានអំណាចលើពួកខ្មាំងសត្រូវ
- ពរខាងវិញ្ញាណ(Spiritual Blessing) – ចូលក្នុងព្រះរាជ្យនៃស្ថានបរមសុខ។

## ការឆ្លើយតប

២កូរិនថូស ៩:៨,១១

[៨] ព្រះអង្គអាចនឹងប្រទានពរដ៏ហូរហៀរគ្រប់យ៉ាងដល់បងប្អូន
ដើម្បីឲ្យបងប្អូន មាន អ្វីៗទាំងអស់ដែលបងប្អូនត្រូវការដ៏ចាំបាច់នោះជានិច្ច
ហើយថែមទាំងនៅសល់បរិបូណ៌សម្រាប់ ចែកទាន ផង
[១១] ព្រះអង្គនឹងធ្វើឲ្យបងប្អូនទៅជាអ្នកមានគ្រប់វិស័យទាំងអស់
ដើម្បីឲ្យបងប្អូនមានចិត្តសទ្ធាជ្រះថ្លាគ្រប់ជំពូក...



ព្រះគ្រិស្តដែលបានលោះអ្នកឲ្យរួចផុតពីបណ្តាសាដែលមកពីក្រឹត្យវិន័យនោះ
បានបង្ហូរពរគ្រប់ប្រការដែលលោកអប្រាហាំបានទទួលដល់អ្នកហើយ។
អ្នកអាចទទួលព្រះពរទាំងនេះពីព្រះយេស៊ូគ្រិស្តបានដោយសារជំនឿ
ហើយអ្នកអាចចែករំលែកព្រះពរទាំងនេះដល់អ្នកដទៃដោយចិត្តសទ្ធាជ្រះថ្លា។

សំណួរបញ្ជាក់ការអនុវត្ត

1. តើអ្នកធ្លាប់ប្រាថ្នាចង់បានពរបែបណាខ្លះមុនពេលទទួលជឿព្រះគ្រិស្ត?
2. សូមរៀបរាប់ពរនីមួយៗដែលអ្នកប្រាថ្នាចង់បានប៉ុន្តែអ្នកមិនទាន់បាននៅឡើយ។
3. តើអ្នកបានទទួលពររួមជាមួយលោកអប្រាហាំហើយឬនៅ?
4. តើអ្នកបានទទួលពររួមជាមួយលោកអប្រាហាំនៅពេលណា? ទទួលរបៀបណា?
5. តើកន្លងមកនេះអ្នកបានទទួលពរអ្វីខ្លះរួមជាមួយលោកអប្រាហាំ?
6. បើមិនទាន់នៅឡើយ តើអ្នកចង់ទទួលពររួមជាមួយអប្រាហាំឬទេ?
7. តើអ្នកបានទទួលពររួមជាមួយលោកអប្រាហាំសម្រាប់តែប្រយោជន៍ខ្លួនឯងផ្ទាល់ ឬសម្រាប់ឲ្យពរដល់អ្នកដទៃផងដែរ?
8. តើអ្នកមានផែនការបែបណាដើម្បីរក្សាជីវិតអ្នកឲ្យបានទទួលពររួមជាមួយ លោកអប្រាហាំជានិច្ច?
9. សូមទន្ទេញនិងសញ្ជឹងគិតបទគម្ពីរ កាឡាទី ៣:៨-៩។